# ទិដ្ឋភាពយេនឌ័រនៅក្នុងសេចក្តីព្រាងច្បាប់ភូមិបាល
# នៃព្រះរាជាណាចក្រកម្ពុជា

ខែមិថុនា ឆ្នាំ២០២៤

## សេចក្តីសង្ខេប និងសារៈសំខាន់ៗ

ខណៈដែលការកាន់កាប់ដីធ្លីប្រកបដោយសុវត្ថិភាពរបស់ស្ត្រី អាចពង្រឹងដល់ការចូលរួម ចំពោះការធ្វើសេចក្តីសំរេចចិត្តក្នុងគ្រួសារ និងសុខមាលភាពរបស់ពួកគេ សេចក្តីព្រាងច្បាប់ភូមិបាលនាពេលថ្មីៗនេះ នៅមានភាពខ្វះខាតនូវបញ្ញត្តិជាក់លាក់ដើម្បីឆ្លើយតបបញ្ហាសមភាពយេនឌ័រដោយប្រសិទ្ធិភាព។

- សេចក្តីព្រាងច្បាប់ភូមិបាល មានភាពកំហិតលើការចែងទាក់ទងនឹងសហព័ទ្ធ (ប្តី-ប្រពន្ធ) មិនមានការចែងអំពីស្ត្រី និងមានត្រឹមតែជាលក្ខណៈពង្រឹងសមភាពយេនឌ័រដោយប្រយោល តាមរយៈការចែងយោងរដ្ឋធម្មនុញ្ញ និងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។
- មាត្រាមួយចំនួននៃសេចក្តីព្រាងច្បាប់ភូមិបាលមានផលប៉ះពាល់យ៉ាងអសមាមាត្រដល់ស្ត្រី ដោយសារតែតួនាទីមានលក្ខណៈដោយឡែករបស់ស្ត្រីនៅជនបទ និងស្ត្រីជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា។
- សេចក្តីព្រាងច្បាប់ភូមិបាល មិនបានឆ្លើយតបទៅនឹងបញ្ហាវិសមភាពដែលមានស្រាប់ចំពោះការចូលរួមរបស់ស្ត្រីក្នុងអភិបាលកិច្ចដីធ្លី និងភាពជាអ្នកដឹកនាំ។
- សេចក្តីស្នើសុំដាក់ធាតុចូលដែលឆ្លុះបញ្ចាំងគោលការណ៍សមភាពយេនឌ័រទៅក្នុងសេចក្តីព្រាងច្បាប់ភូមិបាល មិនត្រូវបានបញ្ចូលនៅក្នុងសេចក្តីព្រាងដែលបានធ្វើបច្ចុប្បន្នភាពទេ។

ប្រសិនសេចក្តីព្រាងច្បាប់ភូមិបាល មិនដាក់បញ្ចូលនូវបទប្បញ្ញត្តិជាក់លាក់ក្នុងគោលបំណងដើម្បីដោះស្រាយបញ្ហាវិសមភាពជាក់ស្តែងទេនោះ វិសមភាពនៅតែបន្ត និងមានបញ្ហាប្រឈមនានាសម្រាប់ស្ត្រីនៅជនបទ ដែលពួកគេតែងតែដើរតួនាទីសំខាន់ក្នុងការធានារក្សាភាពគង់វង្សសេដ្ឋកិច្ចគ្រួសាររបស់ខ្លួន រួមមានទាំងតាមរយៈការងារក្នុងផ្នែកដែលគ្មានប្រាក់ចំណូលនៃសេដ្ឋកិច្ចរបស់ពួកគេ។

## សេចក្តីផ្តើម

សេចក្តីព្រាងច្បាប់ភូមិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបញ្ចេញឱ្យអង្គការសង្គមស៊ីវិលបានដឹងកាលពីខែមករា ឆ្នាំ ២០២៤ (សេចក្តីព្រាងច្បាប់ភូមិបាល ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០២៣)។ បន្ទាប់ពីការផ្តល់ពេលវេលាដ៏មានកំណត់ ដល់អង្គការសង្គមស៊ីវិល ដើម្បីពិនិត្យ និងផ្តល់យោបល់ ក្រសួងរៀបចំដែនដី

នគរូបនីយកម្ម និងសំណាង់បានទទួលយក និងបញ្ចូលយោបល់មួយចំនួនទៅក្នុងសេចក្តីព្រាងច្បាប់នេះ និងបានផ្តល់ឱ្យអង្គការសង្គមស៊ីវិលនូវសេចក្តីព្រាងច្បាប់ភូមិបាលកំណែថ្មីមួយទៀត (ដែលរៀបចំឡើង សម្រាប់សិក្ខាសាលាជាលក្ខណៈអន្តរក្រសួង នៅថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០២៤)។ សេចក្តីព្រាងច្បាប់ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០២៤ នេះ មាន ៧ មាតិកា ១៩០ មាត្រា និងសន្ទានុក្រម។ សេចក្តីវិភាគខាងក្រោមនេះធ្វើឡើងដោយផ្អែកតាមសេចក្តីព្រាងច្បាប់ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០២៤។[1]

អនុស្សរណៈ(សេចក្តីវិភាគ)នេះ ពិនិត្យលើសេចក្តីព្រាងច្បាប់ចេញពីជ្រុងយេនឌ័រ ដោយផ្តោតលើផលប៉ះពាល់ដែលមានលើសិទ្ធិដីធ្លី ជីវភាពរស់នៅ និងសុខមាលភាពរបស់ស្ត្រី។ ការស្រាវជ្រាវបង្ហាញថា កំណើននៃការកាន់កាប់ដីធ្លីប្រកបដោយសុវត្ថិភាពរបស់ស្ត្រី មានឥទ្ធិពលជាវិជ្ជមានលើការចូលរួមរបស់ពួកគេ ក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងគ្រួសារ កម្រិតនៃប្រាក់ចំណូលរបស់គ្រួសារ ចំណាយលើអាហារនិងការអប់រំ និងការថយចុះករណីអំពើហិង្សាក្នុងគ្រួសារ[1] ដែលនេះជាការគូសបញ្ជាក់ពីសារៈសំខាន់នៃច្បាប់នេះ និងពីរបៀបដែលច្បាប់គឺជាឱកាសជួយលើកកម្ពស់ស្ត្រី ដែលកំពុងរស់នៅតាមតំបន់ជនបទនៅប្រទេសកម្ពុជា។

## ក្របខ័ណ្ឌច្បាប់ស្តីពីសិទ្ធិដីធ្លីរបស់ស្ត្រីនៅកម្ពុជា

ច្បាប់សំខាន់ៗដែលចែងពីសិទ្ធិដីធ្លីរបស់ស្ត្រីនៅកម្ពុជា រួមមាន រដ្ឋធម្មនុញ្ញ ក្រមរដ្ឋប្បវេណី និងច្បាប់ភូមិបាល ឆ្នាំ ២០០១។ ដោយហេតុថារដ្ឋធម្មនុញ្ញចែងពីការគោរពតាមអនុសញ្ញានានារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស យើងក៏លើកឡើងផងដែរនូវបញ្ញត្តិសំខាន់ៗ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (ស៊ី-ដ) ដែលជាអនុសញ្ញារបស់អង្គការសហប្រជាជាតិដ៏សំខាន់ស្តីពីស្ត្រី ដូចមានក្នុងទិដ្ឋភាពរួមខាងក្រោម៖

<u>រដ្ឋធម្មនុញ្ញ</u>

រដ្ឋធម្មនុញ្ញបានបញ្ចូលមាត្រាជាច្រើនពាក់ព័ន្ធនឹងសមភាពយេនឌ័រ និងសិទ្ធិកម្មសិទ្ធិលើដីធ្លី ដែលបញ្ជាក់យ៉ាងច្បាស់ថាស្ត្រីមានសិទ្ធិដូចគ្នានឹងបុរស លើកម្មសិទ្ធិ មត៌ក និងការគ្រប់គ្រងដីធ្លី ដូចជា៖

- <u>មាត្រា ៣១៖</u> "...ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការ

[1] សំគាល់៖ ចាប់តាំងពីការតាក់តែងអនុស្សរណៈនេះមក មានការបញ្ចេញនូវកំណែថ្មីនៃសេចក្តីព្រាងច្បាប់ភូមិបាល (ពង្រាងចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤)។ អនុស្សរណៈនេះ មិនបានធ្វើបច្ចុប្បន្នភាពឆ្លុះបញ្ចាំងពីកំណែថ្មីនៃច្បាប់ទេ ប៉ុន្តែការពិនិត្យមើលលើពង្រាងថ្មី បង្ហាញថានៅតែមិនមានការបញ្ចូលសេចក្តីយោងឬចែងទាក់ទងនឹងសមភាពយេនឌ័រ។

នយោបាយ ដើមកំណើត ជាតិ ឋានៈ សង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។...″ មាត្រានេះក៏បាន លើកឡើងពីការគោរពសន្ធិសញ្ញា និងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិនារី និងសិទ្ធិកុមារ។

- <u>មាត្រា ៤៤៖</u> ‶ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។...″
- <u>មាត្រា ៤៥៖</u> ‶ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទត្រូវលុបបំបាត់ចោល.... បុរស និងស្ត្រីមាន សិទ្ធិស្មើគ្នាលើគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ។....″

មាត្រាជាច្រើនដទៃទៀតដែលចែងពីសិទ្ធិ ត្រង់ជំពូកទី III នៃរដ្ឋធម្មនុញ្ញចែងយ៉ាងច្បាស់ថា សិទ្ធិទាំង នេះត្រូវអនុវត្តចំពោះប្រជាពលរដ្ឋកម្ពុជា ‶ទាំងពីរភេទ″។

<u>ក្រមរដ្ឋប្បវេណី</u>

ក្រមរដ្ឋប្បវេណី បញ្ញត្តិអំពីគោលការណ៍ទូទៅដែលទាក់ទងទៅនឹងទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី ហើយដែលបញ្ញត្តិនៃក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តចំពោះទំនាក់ទំនងទ្រព្យសម្បត្តិ និងទំនាក់ទំនងញាតិ (មាត្រា ១), ទស្សនទានជាមូលដ្ឋាននៃក្រមនេះ កំណត់ពីគោលការណ៍នៃការធានាសេចក្តីថ្លៃថ្នូររបស់បុគ្គល ភាពស្មើគ្នារបស់បុរស ស្ត្រី និងសិទ្ធិលើទ្រព្យសម្បត្តិដែលត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ (មាត្រា ២)។

ក្រមនេះក៏ទទួលស្គាល់ផងដែរលើសមត្ថភាពទទួលសិទ្ធិរបស់ស្ត្រី៖ ស្ត្រី និងបុរសមានសមត្ថភាពចុះកិច្ច សន្យាក្រោមលក្ខខណ្ឌ សិទ្ធិ និងកាតព្វកិច្ចជាមូលដ្ឋានដូចគ្នា (មាត្រា ៦, ៨, ១៥ និង ១៦)។

មាត្រាដទៃទៀតដែលចែងពីសមភាពយេនឌ័រទាក់ទងនឹងសិទ្ធិ និងការទទួលមត៌កទ្រព្យសម្បត្តិ មាន ដូចជា៖

- <u>មាត្រា ៩៧១</u>៖ ទទួលស្គាល់ពីការមានកម្មសិទ្ធិរួមគ្នាទាំងស្រុង ឬដោយឡែក ដែលជាប្រព័ន្ធទ្រព្យ សម្បត្តិនៃអាពាហ៍ពិពាហ៍
- <u>មាត្រា ៩៧៣ និង ៩៧៦</u>៖ ចែងពីការយល់ព្រមពីប្តី និងប្រពន្ធ ដែលត្រូវបានកំណត់ជាលក្ខខណ្ឌ សម្រាប់ប្រតិបត្តិការទាំងឡាយដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិនៃអាពាហ៍ពិពាហ៍
- <u>មាត្រា ៩៧៤</u>៖ ទទួលស្គាល់សិទ្ធិស្មើគ្នាក្នុងការធ្វើជាម្ចាស់ ឬគ្រប់គ្រងទ្រព្យសម្បត្តិ ដោយមិនប្រកាន់ពី ប្រភេទនៃអាពាហ៍ពិពាហ៍
- <u>មាត្រា ១១៦១ (១) និង ១១៦២</u>៖ ចែងថា ក្នុងករណីសន្តតិកម្ម សហព័ទ្ធរបស់មត៌កជន មានសិទ្ធិ ទទួលបានចំណែកនៃទ្រព្យសម្បត្តិនៃអាពាហ៍ពិពាហ៍ក្នុងចំណែកអប្បបរមា

- <u>មាត្រា ១១៥៦ (១, ២)</u>៖ ចែងថាបងប្អូនប្រុសស្រីមានសិទ្ធិស្មើគ្នាក្នុងការទទួលមត៌ក និងទទួលបានចំណែកមត៌កស្មើៗគ្នា

<u>អនុសញ្ញា CEDAW</u>

អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី ហៅកាត់ថាអនុសញ្ញា ស៊ី-ដ តម្រូវឱ្យរដ្ឋធ្វើការពិចារណាជាពិសេសលើសិទ្ធិ និងការការពារស្ត្រីនៅជនបទ និងចាត់វិធានការសមស្រប ដើម្បីឆ្លើយតបចំពោះបញ្ហាដែលស្ត្រីនៅជនបទជួបប្រទះ និងការពារពួកគេពីការរើសអើងនានា (មាត្រា ១៤)។ សិទ្ធិរបស់ស្ត្រីនៅជនបទ (មាត្រា ១៤ (២)) រួមមាន សិទ្ធិចូលរួមក្នុងការរៀបចំផែនការអភិវឌ្ឍន៍ ទទួលបានការបណ្តុះបណ្តាលនិងការអប់រំប្រភេទផ្សេងៗ ចងក្រងក្រុមជួយខ្លួនឯង និងសហគមន៍ ដើម្បីទទួលបានឱកាសសេដ្ឋកិច្ច ចូលរួមក្នុងសកម្មភាពនានារបស់សហគមន៍ ទទួលបានឥណទាន និងធនធានកសិកម្ម និងទទួលបានការយកចិត្តទុកដាក់ស្មើគ្នាក្នុងគម្រោងកែទម្រង់ដីធ្លី និងកសិកម្ម ព្រមទាំងគម្រោងបែងចែកដីធ្លី។

អនុសញ្ញា ស៊ី-ដ ក៏តម្រូវឱ្យរដ្ឋចាត់វិធានការសមស្របគ្រប់បែបយ៉ាង ដើម្បីធានាថា បុរស និងស្ត្រីមានសិទ្ធិដូចគ្នា ចំពោះ "កម្មសិទ្ធិ ការទិញ ការគ្រប់គ្រង ការចាត់ចែង ការអាស្រ័យផល និងការប្រគល់ទ្រព្យសម្បត្តិ ទោះដោយមិនគិតថ្លៃក្តី ឬគិតថ្លៃក្តី" (មាត្រា ១៦)។

## កិច្ចពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ភូមិបាល

កាលពីដើមឆ្នាំ ២០២៤ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចែកលិខិតប្រមាណជា ៣.០០០ ច្បាប់ ដើម្បីអញ្ជើញអ្នកពាក់ព័ន្ធឱ្យផ្តល់មតិយោបល់លើសេចក្តីព្រាងច្បាប់ភូមិបាលនេះ។ ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងសម្របសម្រួលប្រមូលធាតុចូលពីអង្គការសង្គមស៊ីវិល អង្គការ Landesa បានសហការជាមួយនឹងអង្គការទិន្នន័យអំពីការអភិវឌ្ឍ (Open Development Cambodia) អង្គការ ALIGN និងដៃគូអភិវឌ្ឍន៍ដទៃទៀត ដើម្បីរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាច្រើនលើក ជាមួយអង្គការសង្គមស៊ីវិល ក្រុមជនជាតិដើមភាគតិច និងអ្នកជំនាញខាងច្បាប់ភូមិបាល។ កិច្ចពិគ្រោះយោបល់ទាំងនេះ រួមមាន សិក្ខាសាលារយៈពេល ២ ថ្ងៃ ដែលមានអ្នកចូលរួមចំនួន ៧២ នាក់ កាលពីថ្ងៃទី ១៣-១៤ ខែកុម្ភៈ និងកិច្ចប្រជុំជាមួយនឹងអ្នកជំនាញបច្ចេកទេសច្បាប់ចំនួន ២១ នាក់ កាលពីថ្ងៃទី ១៥ ខែកុម្ភៈ នៅមុនពេលនៃការស្នើសុំដាក់ធាតុចូល និងយោបល់ កាលពីជុំទី ១ ។ អង្គការក្រៅរដ្ឋាភិបាល NGO Forum ក៏បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់នៅក្នុងអំឡុងពេលនោះផងដែរ។

បន្ទាប់ពីមានការបើកជាថ្មី នូវរយៈពេលសម្រាប់ផ្តល់យោបល់លើ សេចក្តីព្រាងច្បាប់ កាលពីខែមីនា អង្គការ Landesa បានគាំទ្រដល់អង្គការទិន្នន័យអំពីការអភិវឌ្ឍ (Open Development Cambodia) និង អង្គការជាដៃគូក្នុងស្រុកដទៃទៀត ដូចជា GADC, ICSO និង MVi ដើម្បីរៀបចំកិច្ចប្រជុំពិគ្រោះយោបល់បន្ថែម ក្នុងគោលបំណងសម្របសម្រួល និងធ្វើសុខដុមនីយកម្មធាតុចូលដែលទទួលបានពី អង្គការសង្គមស៊ីវិល បង្កើនការយល់ដឹងអំពីបទប្បញ្ញត្តិនៃច្បាប់ភូមិបាល និងចែករំលែកចំណេះដឹងអំពីបញ្ហាដែលអាចកើតចេញពី បញ្ញត្តិនានានៃសេចក្តីព្រាងច្បាប់នេះ។ កិច្ចប្រជុំជាច្រើន ក្នុងចំណោមកិច្ចប្រជុំទាំងនេះ បានផ្តោតការយកចិត្ត ទុកដាក់លើសិទ្ធិរបស់ជនជាតិដើមភាគតិច។ កិច្ចប្រជុំមួយ ដែលជាកិច្ចប្រជុំចែករំលែកចំណេះដឹងអំពីសិទ្ធិដីធ្លី របស់ស្ត្រី ត្រូវបានរៀបចំឡើងដោយអង្គការទិន្នន័យអំពីការអភិវឌ្ឍ (Open Development Cambodia) ដោយមានការចូលរួមសម្របសម្រួលពីអង្គការ GADC ដែលជាដៃគូរបស់អង្គការ Landesa ដោយមានអ្នក ចូលរួមជាអ្នកជំនាញខាងសិទ្ធិស្ត្រីនៅជនបទចំនួន ២២ នាក់ ពិភាក្សាអំពីក្របខ័ណ្ឌច្បាប់ជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធនានា។[2]

អ្នកចូលរួមនៅក្នុងកិច្ចប្រជុំចែករំលែកចំណេះដឹង អំពីសិទ្ធិដីធ្លីរបស់ស្ត្រី បានលើកឡើងអំពីទិដ្ឋភាព សំខាន់ៗមួយចំនួន ដូចខាងក្រោម៖

- ខ្វះការគិតគូរពិចារណាអំពីសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា (LGBTQIA+)[3] ទាក់ទងនឹង មត៌ក ការធ្វើជាម្ចាស់កម្មសិទ្ធិរួមគ្នា និងបញ្ហាសិទ្ធិលើទ្រព្យសម្បត្តិដទៃទៀត។
- ជាការចាំបាច់ត្រូវមានរចនាសម្ព័ន្ធច្បាប់ ដើម្បីគាំទ្រដល់ការពង្រឹងភាពអនុលោមតាមបញ្ញត្តិនៃកិច្ច ព្រមព្រៀងអន្តរជាតិ។ ប្រសិនបើពុំទាន់មានរចនាសម្ព័ន្ធគាំទ្រនេះទេ ចាំបាច់ត្រូវមានកិច្ចខិតខំ ប្រឹងប្រែងផ្តល់ការគាំទ្រចំពោះកិច្ច ដូចជា ជួយសហគមន៍ ក្នុងការចុះបញ្ជី និងចេញសំបុត្រ អាពាហ៍ពិពាហ៍ នៅមុនពេលនៃដំណើរការចុះបញ្ជីកម្មសិទ្ធិដីធ្លីជាលក្ខណៈប្រព័ន្ធ ដើម្បីបំពេញចំណុច ខ្វះខាត។

---

2 អ្នកចូលរួមនៅក្នុងកិច្ចប្រជុំចែករំលែកចំណេះដឹងអំពីសិទ្ធិដីធ្លីរបស់ស្ត្រី អញ្ជើញមកពីអង្គការទិន្នន័យអំពីការអភិវឌ្ឍ (ODC) សមាគមស្ត្រីជនជាតិដើមភាគតិចកម្ពុជា (CIWA) អង្គការក្លាហាន សមាគមធាងត្នោត (STT) អង្គការសមធម៌កម្ពុជា (EC) ក្រុមការងារលើកស្ទួយភាពអង់អាច និងអភិវឌ្ឍន៍សហគមន៍ (CEDT) អង្គការ Landesa អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) វេទិកាអង្គការក្រៅរដ្ឋាភិបាលស្តីពីកម្ពុជា (NGOF) សមាគមសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា (ADHOC) អង្គការសុខភាពគ្រួសារអន្តរជាតិ – គម្រោងគាំទ្រអង្គការសង្គមស៊ីវិល (FHI360-CSS), HBS និងទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID)។

3 អក្សរកាត់ សម្រាប់អត្តសញ្ញាណសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា (ស្រីស្រលាញ់ស្រី ប្រុសស្រលាញ់ប្រុស អ្នកស្រលាញ់ទាំងពីរភេទ អ្នកប្តូរភេទ អត្តសញ្ញាណភេទមិនច្បាស់លាស់ អន្តរភេទ និង/ឬ អ្នកមិនបង្ហាញអត្តសញ្ញាណភេទ)

- រចនាសម្ព័ន្ធដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមានសារៈសំខាន់ ជាពិសេសសម្រាប់ស្ត្រីដែលអាចប្រឈមនឹងការពន្យាពេលវេលាយូរនៅក្នុងការអនុវត្តនីតិវិធីលែងលះ ដែលអាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិដីធ្លីរបស់ពួកគេ។
- "ស្ត្រីមានទឹកចិត្តមោះមុតចំពោះការទទួលបានកម្មសិទ្ធិដីធ្លី ដែលវាត្រូវបានជម្រុញដោយសេចក្តីប្រាថ្នាចង់បានភាពរុងរឿងរបស់ខ្លួន។"
- ទោះបីជាចំនួនសកម្មជនជាស្ត្រីមានការកើនឡើងយ៉ាងណាក៏ដោយ ក៏ បុរសនៅតែបន្តជាអ្នកមានឥទ្ធពលគ្របដណ្តប់លើកិច្ចខិតខំខាងការបញ្ចុះបញ្ចូល ក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិច។ បញ្ហានេះ រងឥទ្ធិពលដោយសារ កត្តាអប់រំ បទដ្ឋានវប្បធម៌ និងតួនាទីបែបប្រពៃណី។ ដើម្បីគាំទ្រដល់ការចូលរួមរយៈពេលវែងរបស់ស្ត្រី គេចាំបាច់ត្រូវឆ្លើយតបចំពោះឧបសគ្គទាំងឡាយ ដូចជា ការមិនចូលរួមសហការនៅដំណាក់កាលដំបូងៗ និងការរំពឹងទុកផ្នែកវប្បធម៌ជាដើម។
- ទំនាក់ទំនងរបស់ស្ត្រីជាមួយនឹងដីធ្លី មិនអាចកាត់ផ្តាច់បានពីការទទួលខុសត្រូវរបស់ពួកគេ ក្នុងនាមជាអ្នកប្រមូលផល និងអ្នកធ្វើកសិកម្មឡើយ។ ទោះជាយ៉ាងនេះក្តី បុរសជាអ្នកធ្វើការសម្រេចចិត្តភាគច្រើនលើបញ្ហាពាក់ព័ន្ធនឹងកម្មសិទ្ធិដីធ្លី ជាពិសេស ក្នុងសហគមន៍ជនជាតិដើមភាគតិច ដែលចាស់ព្រឹទ្ធាចារ្យជនជាតិដើមភាគតិចជាអ្នកដែលមានអំណាច។
- នៅពេលដែលស្ត្រីជនជាតិដើមភាគតិចដាក់ពាក្យបណ្តឹងតាមក្រុមរដ្ឋប្បវេណី អំពីការកាប់ឈើ ឬការទន្ទ្រានដីខុសច្បាប់ ដែលជាធម្មតា កិច្ចការនេះត្រូវការចំណាយពេលវេលា និងធនធានយ៉ាងច្រើននោះ ជាញឹកញាប់ ពួកគេទទួលបានការគាំទ្រ ឬការលើកទឹកចិត្តតិចតួចប៉ុណ្ណោះ។ ពួកគេក៏ជួបប្រទះនឹងបញ្ហាប្រឈមជាក់ស្តែងផងដែរ ដូចជា ស្នើសុំមិនចូលរួមក្នុងនីតិវិធីតុលាការជាមួយនឹងកូនៗរបស់ពួកគេ ដ្បិតពួកគេបារម្ភថា វត្តមានរបស់កូនៗអាចបង្កការរំខានដល់ដំណើរការនីតិវិធីជាដើម។
- ដើម្បីសម្រួលដល់ការអនុវត្តច្បាប់ប្រកបដោយជោគជ័យ និងសមធម៌ គួរមានការបញ្ជាក់ឱ្យបានច្បាស់ៗ លើពាក្យថា "អាជ្ញាធរមានសមត្ថកិច្ច" និងពាក្យពេចន៍ដែលមានភាពស្រពេចស្រពិលដទៃទៀតនៅក្នុងច្បាប់ភូមិបាល។

## ទិដ្ឋភាពយេនឌ័រនៅក្នុងសេចក្តីព្រាងច្បាប់ភូមិបាល

សេចក្តីព្រាងច្បាប់ភូមិបាលនៃព្រះរាជាណាចក្រកម្ពុជា លើកឡើងតិចតួចប៉ុណ្ណោះអំពីស្ត្រី និងយេនឌ័រ ទោះបីជាមានការផ្តល់យោបល់ពីអង្គការសង្គមស៊ីវិល ឲ្យផ្តល់អាទិភាពលើបញ្ហាសមភាពយេនឌ័រៈ

១. **ការពង្រឹងសមភាពយេនឌ័រ ធ្វើឡើងបែបប្រយោល តាមរយៈការលើកឡើងពី រដ្ឋធម្មនុញ្ញ និង ក្រមរដ្ឋប្បវេណី។** ជាមួយនឹងការបញ្ជាក់ពីទំនាក់ទំនងរវាងច្បាប់ភូមិបាល និងក្រមរដ្ឋប្បវេណី និងរដ្ឋធម្មនុញ្ញនៅក្នុងមាត្រា ៦ និង ៨ សេចក្តីព្រាងច្បាប់នេះទទួលស្គាល់សមភាពយេនឌ័រដោយប្រយោល ដូចជា សិទ្ធិកម្មសិទ្ធិ មត៌ក ឬការគ្រប់គ្រងទ្រព្យសម្បត្តិ ជាដើម ដោយយោងលើច្បាប់ពាក់ព័ន្ធ។ ក្រោមមាត្រា ៦ និង ៨ រាល់បញ្ញាទាំងអស់នៃក្រមរដ្ឋប្បវេណី និងរដ្ឋធម្មនុញ្ញ រាប់បញ្ចូលទាំងបញ្ញត្តិដែលគាំទ្រដល់សិទ្ធិស្មើគ្នារបស់ស្ត្រី ត្រូវបានអនុវត្តក្នុងក្របខ័ណ្ឌច្បាប់ភូមិបាល លើកលែងតែមានការចែងផ្សេងក្នុងច្បាប់នេះ។ សេចក្តីព្រាងច្បាប់ភូមិបាល ពុំបានបញ្ចូលបញ្ញត្តិទាំងឡាយណាដែលប៉ះពាល់ យ៉ាងជាក់ច្បាស់លើសិទ្ធិស្មើគ្នារបស់ស្ត្រីឡើយ ដូច្នេះគោលការណ៍សមភាពយេនឌ័រ ដូចចែងនៅក្នុងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១-២ នៃក្រមរដ្ឋប្បវេណី គួរពង្រីកវិសាលភាពបន្ថែមទៀត តាមរយៈការអនុវត្តច្បាប់នេះ។

- មាត្រា ៦ ពិភាក្សាពីទំនាក់ទំនងរវាងក្រមរដ្ឋប្បវេណី និងច្បាប់ភូមិបាល ដោយចែងថា "បញ្ញត្តិក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្ត... លើកលែងតែមានកំណត់ផ្សេងនៅក្នុងច្បាប់នេះ។"
- មាត្រា ៨ លើកឡើងពីបញ្ញត្តិស្តីពីកម្មសិទ្ធិដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ដោយចែងថា "បញ្ញត្តិស្តីពីកម្មសិទ្ធិដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ អនុវត្តទៅលើ អចលនវត្ថុទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា តាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងច្បាប់នេះ ក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានផ្សេងទៀត។"

២. **មិនមានការលើកឡើងដោយជាក់លាក់អំពីស្ត្រីនៅក្នុងខ្លឹមសារច្បាប់នេះឡើយ ប៉ុន្តែមានការលើកឡើងពីសិទ្ធិរបស់ប្តីប្រពន្ធលើទ្រព្យសម្បត្តិរួម។** មាត្រាចំនួន ៣ លើកឡើងពីប្តីប្រពន្ធ ដែលសំដៅលើស្ត្រីផងដែរ ក្នុងបរិបទនៃទ្រព្យសម្បត្តិរួម៖

- មាត្រា ១៦៥ ស្តីពីការស្នើសុំចុះបញ្ជីជាឯកតោភាគីចែងថា ការផ្ទេរសិទ្ធិពីទ្រព្យសម្បត្តិរួមប្តីប្រពន្ធទៅជាកម្មសិទ្ធិអវិភាគ ដោយមូលហេតុមរណៈភាពរបស់សហព័ទ្ធណាម្ខាង។
- មាត្រា ១៨០ ស្តីពីការចុះបញ្ជីទ្រព្យសម្បត្តិរួមប្តីប្រពន្ធដែលចែងថា សិទ្ធិដែលកើតឡើងដោយផ្អែកលើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធមិនអាចតតាំង និងតតិយជនបានឡើយ សិទ្ធិនោះពុំបានធ្វើការចុះបញ្ជីនៅរដ្ឋបាលសុរិយោដីទេ។
- មាត្រា ១៨២ ស្តីពីចំណុចដែលត្រូវចុះបញ្ជី ដែលលើកឡើងថាទ្រព្យសម្បត្តិរួមប្តីប្រពន្ធ គឺជាចំណុចដែលត្រូវចុះបញ្ជី។

ពាក្យថា "សហព័ទ្ធ" ជាភាសាខ្មែរសំដៅលើប្ដី និងប្រពន្ធ ហើយនៅក្នុងច្បាប់នេះគេយល់ថាតម្រូវឱ្យមានការចងសម្ព័ន្ធតាមរយៈប័ណ្ណអាពាហ៍ពិពាហ៍ ដូច្នេះបញ្ញត្តិនេះ និងបញ្ញត្តិដែលពាក់ព័ន្ធ ផាត់ចេញពីដំណើរការចុះបញ្ជីដីរួមគ្នាចំពោះអ្នកដែលរស់នៅជាមួយគ្នាបែបប្រពៃណី តែពុំមានសំបុត្រអាពាហ៍ពិពាហ៍ផ្លូវការ ក៏ដូចជាសមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា (LGBTQIA+) ជាដើម។

៣. **បើទោះជាមានការលើកឡើងតិចតួចពីស្ត្រី និងពីសមភាពតាមច្បាប់ ក៏ដោយ ក៏ច្បាប់ភូមិបាលមានបញ្ញត្តិជាច្រើន ដែលមានផលប៉ះពាល់ផ្អែកតាមយេនឌ័រ ដោយសារតែស្ថានភាពរបស់ស្ត្រីនៅជនបទក្នុងប្រទេសកម្ពុជា**។ ផលប៉ះពាល់ផ្អែកតាមយេនឌ័រជាច្រើន ក្នុងចំណោមផលប៉ះពាល់ទាំងនេះ នាំឱ្យស្ត្រីមានអំណាចកាន់តែតិចជាងមុន ហើយកាន់តែប្រឈមនឹងហានិភ័យ ដោយមានករណីលើកលែងតែមួយចំនួនតែប៉ុណ្ណោះ។ ការខកខានពុំបានទទួលស្គាល់ ក៏ដូចជាឆ្លើយតបចំពោះផលប៉ះពាល់មិនសមាមាត្រទាំងនេះ ជាហេតុនាំឱ្យគម្លាតយេនឌ័ររវាងស្ត្រី និងបុរសនៅតំបន់ជនបទនៃប្រទេសកម្ពុជារីកកាន់តែធំ។

- <u>មាត្រា ២៩ និង ១១៦</u>៖ ការហាមប្រាមការកាន់កាប់ក្រោយឆ្នាំ ២០០១ អាចធ្វើឱ្យស្ត្រីដែលបាន និងកំពុងប្រើប្រាស់ដីសាធារណៈរាប់ទសវត្សរ៍មកហើយ ពុំមានច្រក ដើម្បីឈានទៅទទួលបានសិទ្ធិកាន់កាប់ដីធ្លីដោយគត់ម៉ត់។ វាអាចបង្កផលប៉ះពាល់យ៉ាងធំធេងមកលើជីវភាពរស់នៅ និងសុខមាលភាពរបស់ស្ត្រី ទាក់ទងនឹង ការប្រើប្រាស់ធនធានព្រៃឈើជាក់ស្ដែង រួមទាំង ការប្រមូលអនុផលព្រៃឈើ និងទឹក ដោយហេតុថា ស្ត្រីច្រើនតែមានទំនាក់ទំនងក្រៅផ្លូវការជាមួយនឹងដីធ្លីច្រើនជាងបុរស ជាពិសេស នៅក្នុងសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍បែបប្រពៃណីដទៃទៀត [2]។

- <u>មាត្រា ៣៨</u>៖ ស្រដៀងគ្នានឹងមាត្រា ២៩ ដែរ បញ្ញត្តិនេះផាត់ចេញនូវដីដែលធ្លាប់តែប្រើប្រាស់បែបប្រពៃណីដោយស្ត្រី ក្នុងអត្រាមួយខ្ពស់។ បញ្ញត្តិនេះដកតំបន់ដីព្រៃ ដែលត្រូវបានកំណត់ជាតំបន់សម្រាប់ប្រមូលអនុផលព្រៃឈើ និងប្រើប្រាស់ទឹក ចេញពីដីជនជាតិដើមភាគតិច សម្រាប់គោលបំណងផ្ដល់ប័ណ្ណកម្មសិទ្ធិសមូហភាពសហគមន៍។ ខណៈពេលដែលមាត្រានេះចែងថា ការប្រើប្រាស់នៅតែអាចបន្តមាន ប៉ុន្តែការចូលប្រើប្រាស់នេះ ត្រូវមានកិច្ចព្រមព្រៀងជាមួយនឹងអាជ្ញាធរដែលពាក់ព័ន្ធ ដែលអាចនាំឱ្យមានការបដិសេធ ការអនុញ្ញាតឱ្យបន្តប្រើប្រាស់។ ការផាត់ចេញបែបនេះ បង្កផលប៉ះពាល់ច្រើនលើសលប់លើស្ត្រីជនជាតិដើមភាគតិច ដែលធ្លាប់តែប្រើប្រាស់ព្រៃឈើបែបប្រពៃណីក្នុងការស្វែងរកអាហារបន្ថែមដល់គ្រួសារ និងផ្លាស់ប្ដូរកម្លាំងពលកម្មជាមួយនឹងគ្រួសារដទៃទៀត [3]។

- <u>មាត្រា ៣៩</u>៖ ការរៀបចំវិធានបែបប្រពៃណីឱ្យមានលក្ខណៈផ្លូវការ ដូចចែងក្នុងបញ្ញត្តិនេះ អាចបង្កឱ្យមានការរើសអើងយេនឌ័រដោយប្រយោល។ បើទោះជាសហគមន៍ជនជាតិដើមភាគតិចជាច្រើន នៅកម្ពុជាគោរពគុណតម្លៃសមភាពយេនឌ័រ និងការដឹកនាំរបស់ស្ត្រីក៏ដោយ ការដែលច្បាប់ពុំមានបញ្ញត្តិកំណត់ឱ្យបានច្បាស់លាស់អំពីការផ្តល់អាទិភាពដល់សមភាពយេនឌ័រ ដើម្បីមានអានុភាពលុបលើច្បាប់បែបប្រពៃណីដែលមានលក្ខណៈរើសអើង វាអាចជាការគាំទ្រដល់ការអនុវត្តដែលរើសអើង។ អនុសាសន៍នេះ ស្របតាមការណែនាំដែលត្រូវបានផ្តល់នៅក្នុងផ្នែក ៩.២, ៩.៤ និង ៩.៦ នៃគោលការណ៍ណែនាំស្ម័គ្រចិត្តស្តីពី អភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវ លើសិទ្ធិគ្រប់គ្រងដីធ្លី ធនជាននេសាទ និងព្រៃឈើនៅក្នុងបរិបទសន្តិសុខស្បៀងនៅក្នុងប្រទេស(VGGT) [4]។

- <u>មាត្រា ៤០</u>៖ ការផ្តល់ដី និង/ឬសំណងដល់អ្នកដែលចូល ឬចេញពីសហគមន៍ទៅតាមការកំណត់ក្នុងលក្ខន្តិកៈរបស់សហគមន៍ អាចនាំឱ្យមានការរើសអើងលើស្ត្រី ហើយដែលពួកគេជាអ្នកប្រឈមនឹងហានិភ័យខ្ពស់នៃការផាត់ចេញពីសង្គម បន្ទាប់ពីជីវិតមានការផ្លាស់ប្តូរ ដូចជា ការលែងលះ ការក្លាយជាស្ត្រីមេម៉ាយ ។ល។ ហើយជារឿយៗ ពួកគេមានដីទំហំតូចៗដែលមានតម្លៃទាប [5]។

- <u>មាត្រា ៦១</u>៖ ស្រដៀងគ្នានឹងមាត្រា ២៩ និង ៣៨ ដែរ បញ្ញត្តិនេះចែងពីការរឹតត្បិតលើការចូលប្រើប្រាស់ព្រៃឈើ ដើម្បីប្រមូលអនុផលព្រៃឈើ និងប្រើប្រាស់ទឹក។ ការស្រាវជ្រាវនៅក្នុងខេត្តរតនគិរីបង្ហាញថា ការផ្តល់សម្បទានដីសេដ្ឋកិច្ចនៅក្នុងតំបន់ជនជាតិដើមភាគតិច ធ្វើឱ្យបន្ទុកការងារជារួមរបស់ស្ត្រីមានការកើនឡើង ព្រោះពួកគេត្រូវស្វែងរកការងារជាអ្នកស៊ីឈ្នួលធ្វើកសិកម្ម ហើយកូនស្រីរបស់ពួកគេត្រូវបំពេញការងារជាអ្នកផ្តល់ការថែទាំ ដែលនាំឱ្យមានការកើតឡើងជាថ្មីនូវ គម្លាតយេនឌ័រជុំវិញកម្រិតនៃការអប់រំ និងអក្ខរកម្មរបស់ក្មេងស្រី ដែលបញ្ហានេះគួរតែរួមតូចទៅវិញប្រសិនបើពុំមានការផ្តល់ដីសម្បទានដីសេដ្ឋកិច្ចបែបនេះ [2]។

- <u>មាត្រា ៦៤</u>៖ ការខ្វះការកំណត់គោលការណ៍ឱ្យបានច្បាស់លាស់នៅក្នុងច្បាប់ភូមិបាល អំពីរបៀបជ្រើសរើស កំណត់ និងបែងចែកដីសម្បទានធ្វើឱ្យស្ត្រីងាយនឹងទទួលរងការរើសអើង និងការមិនយកចិត្តទុកដាក់ ទាំងអ្នកដែលទទួលបានដីសម្បទាន ទាំងក្នុងការរៀបចំផែនការដីសម្បទាន។ នេះជាចំណុចដែលមានសារៈសំខាន់ជាពិសេស ដ្បិតការយល់ឃើញអំពីការពិគ្រោះយោបល់ប្រកបដោយប្រសិទ្ធភាព និងការរៀបចំផែនការដីសម្បទានប្រកបដោយបរិយាប័ន្ន គឺមានទំនាក់ទំនងខ្លាំងជាមួយនឹងការយល់ឃើញអំពីសមធម៌ ភាពត្រឹមត្រូវ និងការពេញចិត្ត [6]។

- <u>មាត្រា ៦៨</u>៖ មាត្រានេះខកខានពុំបានចែងពីសន្តតិជន ជាពិសេសអំពីស្រ្តីមេម៉ាយ ដែលអាចបន្តអនុវត្តសិទ្ធិលើដីសម្បទាន ក្រោយពេលនៃការបាត់បង់ជីវិតរបស់សម្បទានិក ខណៈពេលដែលសិទ្ធិស្រដៀងគ្នានេះ មានចែងនៅក្នុងមាត្រា ៧១ ស្តីពីសម្បទានដីសេដ្ឋកិច្ច។ បើទោះជាអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (អនុក្រឹត្យលេខ ១៩) ពិតជាបានអនុញ្ញាតឱ្យមានសន្តតិកម្មលើសម្បទានដីសង្គមកិច្ចចំពោះសន្តតិជន ដូចចែងនៅក្នុងមាត្រា ១៨ ក៏ដោយ សិទ្ធិដែលត្រូវបានកំណត់ក្រោមអនុក្រឹត្យនេះ ពុំមានទម្ងន់ធ្ងន់ ដូចគ្នានឹងករណីដែលសិទ្ធិទាំងនេះមានចែងនៅក្នុងច្បាប់ភូមិបាលឡើយ។ សង្គតិភាពរវាងមាត្រាទាំងពីរ (មាត្រា៦៨ និង ៧១) អាចគូសបញ្ជាក់ពីការផ្តល់សារៈសំខាន់ស្មើភាពគ្នាដល់សម្បទានិកនៃសម្បទានដីសង្គមកិច្ច និងសម្បទានិកនៃសម្បទានដីសេដ្ឋកិច្ច។

- <u>មាត្រា ៧២</u>៖ មាត្រានេះជួយការពារផលប្រយោជន៍ តាមរយៈការធានាថា នឹងមិនមានការផ្តល់ដីសម្បទានលើតំបន់ដែលជាវាលស្មៅគង្វាលសត្វ បឹង និងអាងស្តុកទឹកនោះឡើយ។

- <u>មាត្រា ១២៦ ដល់ ១៣៣</u>៖ ស្វ័យភាពដែលត្រូវបានផ្តល់ដល់មន្ត្រីក្នុងការទំនាក់ទំនង និងសួរនាំអ្នកកាន់កាប់ ក្នុងអំឡុងពេលចុះបញ្ជីដីជាលក្ខណៈប្រព័ន្ធ អាចនឹងធ្វើឱ្យមានការផាត់ចេញសម្លេងស្រ្តី ប្រសិនបើមន្ត្រីផ្តល់អាទិភាពដល់យោបល់ និងភ័ស្តុតាងក្នុងការកំណត់ព្រំប្រទល់ដីដែលផ្តល់ដោយបុរស។

លើសពីនេះ បញ្ញត្តិក្នុងមាត្រាទាំងនេះ ក៏ដូចជាមាត្រាដទៃទៀត (ដូចជាមាត្រា ១១៨) ជាដើម ដែលពាក់ព័ន្ធនឹងដំណោះស្រាយវិវាទ ទាក់ទងនឹងបញ្ហាចម្បងដែលស្រ្តីនៅជនបទក្នុងប្រទេសកម្ពុជាកំពុងប្រឈម។ ការសិក្សាបង្ហាញថា ជម្លោះដីធ្លីបង្កផលប៉ះពាល់យ៉ាងធំធេងលើអំពើហិង្សាបង្កឡើងដោយដៃគូស្និទ្ធស្នាលនៅកម្ពុជា ដែលក្នុងនោះស្រ្តីដែលបានចូលរួមក្នុងការអង្កេតដែលធ្វើឡើងដោយអង្គការ CCHR ចំនួន ៥៣,៩% បានរាយការណ៍ថាពួកគេមិនដែលទទួលរងអំពើហិង្សាក្នុងគ្រួសារឡើយ នៅមុនពេលជម្លោះដីធ្លីកើតមានឡើង [7]។

៤. **គម្លាតដែលកំពុងមាននាពេលបច្ចុប្បន្នទាក់ទិននឹងការកាន់តួនាទីជាអ្នកដឹកនាំរបស់ស្រ្តី ជាកត្តាជាក់កំហិតលើការគ្រប់គ្រង និងអភិបាលកិច្ចដីធ្លីប្រកបដោយប្រសិទ្ធភាព និងសមធម៌ ដែលវាជាបញ្ហាដែលពុំបានទទួលការឆ្លើយតបនៅក្នុងសេចក្តីព្រាងច្បាប់នេះឡើយ។** សេចក្តីព្រាងច្បាប់ភូមិបាលពុំបានលើកឡើងពីបញ្ហាពាក់ព័ន្ធនឹងរចនាសម្ព័ន្ធអភិបាលកិច្ចដីធ្លីនោះឡើយ។ ការពុំលើកឡើងបែបនេះ បន្តស្ថានភាពបច្ចុប្បន្ននៃស្ថាប័នអភិបាលកិច្ច និងរដ្ឋបាលដីធ្លីពុំមានសមធម៌ ហើយដែលនៅបន្តដំណើរការដោយពុំមានការចូលរួមប្រកបដោយអត្ថន័យពីស្រ្តី ឬពុំមានការចូលរួមពីស្រ្តីទាល់តែសោះនៅក្នុងករណី

មួយចំនួន នៅគ្រប់កម្រិតទាំងអស់នៃអភិបាលកិច្ច។ សេចក្តីព្រាងច្បាប់ភូមិបាល គឺជា ឱកាសមួយដ៏សំខាន់ ដើម្បីឆ្លើយតបចំពោះបញ្ហាដែលមានស្រាប់ទាំងនេះ និងផ្តល់នូវក្របខណ្ឌមួយដែលអាចឱ្យគេឆ្លើយតបជាបណ្តើរៗចំពោះវិសមភាពយេនឌ័រដែលកំពុងមាននាពេលបច្ចុប្បន្ន។ ភស្តុតាងមួយចំនួនដែលបង្ហាញពីវិសមភាពនាពេលបច្ចុប្បន្ន មានដូចជា៖

- បើយោងតាម UNIDO ខណៈពេលដែលអ្នកធ្វើការនៅក្នុងវិស័យកសិកម្មជាងពាក់កណ្តាលនៅកម្ពុជា គឺជាស្ត្រី "មានអ្នកគ្រប់គ្រងសហគ្រាសកសិកម្មជាលក្ខណៈគ្រួសារតែ២៤% មន្ត្រីផ្សព្វផ្សាយកសិកម្ម ១២% និងអ្នកទទួលផលពីសេវាផ្សព្វផ្សាយកសិកម្មតែ ១០% ប៉ុណ្ណោះ ដែលជាស្ត្រី" [8]។
- ស្ត្រីដែលកាន់តួនាទីដឹកនាំដោះស្រាយជម្លោះដីធ្លីពុំបានរាយការណ៍ ថាពួកគេអាចទទួលបានការសម្រេចចិត្តនៅកម្រិតខ្ពស់ ក្រោយពេលដែលជម្លោះត្រូវបានដោះស្រាយចប់នោះឡើយ [9, 10] ។
- ការសិក្សាមួយដែលធ្វើឡើងដោយធនាគារពិភពលោក កាលពីឆ្នាំ ២០២០ បានរកឃើញថាកម្លាំងពលកម្មនៅក្នុងវិស័យកសិកម្មជាង ៤០% នៅកម្ពុជា គឺជាស្ត្រី ប៉ុន្តែស្ទើរតែពុំមានស្ត្រីដែលកាន់តួនាទីជាអ្នកគ្រប់គ្រង [11]។
- របាយការណ៍មួយដែលផលិតដោយសមាគមស្ត្រីជនជាតិដើមភាគតិចនៅកម្ពុជា បានរកឃើញថាស្ត្រីជនជាតិដើមភាគតិច មិនអាចចូលរួមប្រកបដោយអត្ថន័យក្នុងការងារអភិបាលកិច្ចឡើយ ពួកគេក៏ពុំមានតំណាងគ្រប់គ្រាន់នៅក្នុងអាជ្ញាធរផ្លូវការ ហើយតួនាទីដែលផ្តល់ឱ្យពួកគេត្រូវបានកំហិតត្រឹមតែការងារដែលចាត់ទុកថាជា "បញ្ហារបស់ស្ត្រី" តែប៉ុណ្ណោះ [12]។
- ស្ត្រីត្រូវបានផ្តល់ឱ្យនូវសមត្ថភាពតាមផ្លូវច្បាប់ស្មើគ្នានឹងបុរសក្រោមរដ្ឋធម្មនុញ្ញ ប៉ុន្តែមានកត្តារចនាសម្ព័ន្ធ និងកត្តាវប្បធម៌ជាច្រើនដែលដាក់កំហិតលើវត្តមានរបស់ពួកគេក្នុងការកាន់តួនាទីជាអ្នកដឹកនាំនៅគ្រប់កម្រិតទាំងអស់នៃអភិបាលកិច្ចដីធ្លី [13].

៥. **អង្គការ Landesa និងអង្គការដៃគូ បានស្នើសុំឱ្យមានការបញ្ចូលគោលការណ៍សមភាពយេនឌ័រ និងគោលការណ៍មិនរើសអើង ទៅក្នុងមាត្រាជាច្រើននៃសេចក្តីព្រាងច្បាប់នេះ។** សេចក្តីព្រាងច្បាប់ភូមិបាល បញ្ចូលនូវការលើកឡើងដដែលៗអំពីគោលការណ៍ដែលមានការកំណត់ជាស្រេច ដែលមានចែងផងដែរនៅក្នុងរដ្ឋធម្មនុញ្ញ និងក្រមរដ្ឋប្បវេណី។ ប៉ុន្តែ ពាក្យថា សមភាពយេនឌ័រ និងការមិនរើសអើង ពុំត្រូវបានលើកឡើងដដែលៗនៅក្នុងខ្លឹមសារនៃច្បាប់នេះឡើយ។ ដូច្នេះ អ្នកពិនិត្យមើលលើសេចក្តីព្រាងច្បាប់នេះ ស្នើសុំឱ្យមានការបញ្ចូលចំណុចដូចខាងក្រោម ក្នុងចំណោមចំណុចជាច្រើនដទៃទៀត៖

- <u>មាត្រា ១</u>៖ កែសម្រួលគោលបំណងច្បាប់ដែលបានចែង ដោយបញ្ចូលនូវពាក្យពេចន៍ដូចមានសរសេរជាអក្សរទ្រេតដូចតទៅនេះ៖ "ធានាការការពារកម្មសិទ្ធិ និងសិទ្ធិផ្សេងទៀតពាក់ព័ន្ធនឹងដី និងអចលនវត្ថុរបស់បុគ្គលឯកជន *ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ស្ត្រី យុវជន និងក្រុមងាយរងគ្រោះ*"។
- មាត្រា ៥៖ បន្ថែមគោលការណ៍ចំនួន ២ ទៀត៖
  - "ធានាសមធម៌ តម្លាភាព និងគណនេយ្យភាពក្នុងការបែងចែក និងគ្រប់គ្រងសិទ្ធិដីធ្លី"។
  - "ធានាសិទ្ធិស្មើគ្នារវាងស្ត្រី និងបុរស លើសិទ្ធិកម្មសិទ្ធិ កាន់កាប់ ប្រើប្រាស់ មត៌ក សន្តតិកម្ម ឬចាត់ចែងដីធ្លី"។

## ភាពចាំបាច់ក្នុងការបន្តផ្តល់ការគាំទ្រដល់សិទ្ធិដីធ្លីរបស់ស្ត្រី

ដោយសារតែមាត្រាមួយចំនួននៅក្នុងច្បាប់ភូមិបាលនេះ ចែងសំដៅដល់លក្ខខណ្ឌ និងនីតិវិធី ដែលនឹងត្រូវកំណត់ដោយអនុក្រឹត្យ ជាជំហានឆ្ពោះទៅមុខនោះគឺការរៀបចំសេចក្តីព្រាងនៃអនុក្រឹត្យទាំងនោះ ដែលត្រូវគួរគិតគូរពិចារណាពីគោលការណ៍សមធម៌យេនឌ័រ និងគោលការណ៍មិនរើសអើង ដើម្បីសម្រេចបានសមធម៌សម្រាប់ស្ត្រី ដែលជាលទ្ធផល។ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្ត ដូចមានចែងក្នុងសេចក្តីព្រាងច្បាប់ភូមិបាលនេះ ហើយដែលនឹងត្រូវរៀបចំដោយក្រសួងពាក់ព័ន្ធ ក្រោយការអនុម័តច្បាប់ភូមិបាល មានចងក្រងជាបញ្ជីដូចមានក្នុងឧបសម្ព័ន្ធភ្ជាប់ជូនស្រាប់។ អនុក្រឹត្យទាំងនេះ គឺជាឱកាសមួយដ៏សំខាន់ ដើម្បីឱ្យការអនុវត្តច្បាប់នេះអាចដំណើរការទៅបានប្រកបដោយប្រសិទ្ធភាព។ បើយោងតាមអង្គការ FAO ប្រសិទ្ធភាពនៃច្បាប់ភូមិបាលដែលរៀបចំបានល្អ ជារឿយៗ អាស្រ័យលើការមានច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីសម្រាប់គាំទ្រការអនុវត្ត [14]។

អង្គការ Landesa នឹងពិនិត្យតាមដានលើការរៀបចំនូវអនុក្រឹត្យសំខាន់ៗ ក៏ដូចជាត្រៀមខ្លួនដើម្បីជួយដល់សមាជិកសភា ដើម្បីធ្វើការវិភាគបែបបច្ចេកទេសដែលចាំបាច់ ទៅតាមការស្នើសុំ។

ក្រៅតែពីខ្លឹមសារនៃច្បាប់ភូមិបាល និងអនុក្រឹត្យដែលពាក់ព័ន្ធ ការផ្លាស់ប្តូរជាវិជ្ជមាន ដើម្បីឈានទៅសម្រេចសមភាពយេនឌ័រ និងលើកស្ទួយភាពអង់អាចស្ត្រីក្នុងកិច្ចអភិបាលកិច្ចដីធ្លី និងកម្មសិទ្ធិដីធ្លី ទាមទារឱ្យមានការចូលរួមប្រាស្រ័យទាក់ទងជាមួយស្ត្រីនៅជនបទយ៉ាងសកម្មបំផុត តាមរយៈ "ការអនុវត្តគោលការណ៍រើសអើងបែបវិជ្ជមាន (positive discrimination)" ការកំណត់គោលដៅនៃការប្រើប្រាស់ធនធាន និងកម្មវិធីនានា ដើម្បីលើកកម្ពស់ និងការពារសិទ្ធិដីធ្លីរបស់ស្ត្រី [15]។

មានតែក្របខ័ណ្ឌច្បាប់ដែលឆ្លើយតបចំពោះយេនឌ័រតែប៉ុណ្ណោះ ដែលអាចបង្កើតនូវបរិយាកាស អំណោយផលដល់ការសម្រេចបានសមភាពជាក់ស្តែង (de facto) ទន្ទឹមគ្នានឹងសមភាពដែលមានចែងនៅក្នុងច្បាប់របស់កម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ បើសេចក្តីព្រាងច្បាប់នេះមិនដាក់បញ្ចូលនូវបទប្បញ្ញត្តិជាក់លាក់ ដើម្បីគាំទ្រដ៏រឹងមាំដល់សមភាពយេនឌ័រ និងការមិនរើសអើង លើវិស័យកម្មសិទ្ធិ សិទ្ធិប្រើប្រាស់និងកាន់កាប់ដីធ្លីទេនោះ ច្បាប់ថ្មីនេះមិនទំនងជាអាចឆ្លើយតបចំពោះគម្លាតយេនឌ័រនៅតំបន់ជនបទនៃប្រទេសកម្ពុជាឡើយ។

## ឯកសារយោង

[1] USAID. (2016) Land Tenure, Property Rights, and Gender: Challenges and Approaches for Strengthening Women's Land Tenure and Property Rights. USAID Issue Brief. https://www.land-links.org/wp-content/uploads/2016/09/USAID_Land_Tenure_Gender_Brief_061214-1.pdf

[2] Joshi, S. (2020) Working Wives: Gender, Labour and Land Commercialization in Ratanakiri, Cambodia. Globalizations, 17(1), 1-15. https://doi.org/10.1080/14747731.2019.1586117

[3] United Nations Cambodia. (2022) Gender Equality Deep-Dive for Cambodia: Common Country Analysis. https://cambodia.un.org/en/174010-gender-equality-deep-dive-cambodia

[4] FAO. (2022) Voluntary Guidelines on the Responsible Governance of Tenure of Land, Fisheries and Forests in the Context of National Food Security. First revision. Rome. https://doi.org/10.4060/i2801

[5] Joshi, S. (2018) Gendered Impacts of Land Commercialization in Cambodia. https://repository.graduateinstitute.ch/record/296074/files/Demeter_Research_Brief_1_2705_e-edition.pdf

[6] OHCHR Cambodia. (2018) Assessing the Impact of Social Land Concessions on Rural Livelihoods in Cambodia. https://data.opendevelopmentmekong.net/dataset/a279d227-5db1-46b6-8e8f-e521a98a8748/resource/0a7ccbfb-a1a3-4b67-a3e7-d01f5407728c/download/assessing-the-impact-of-social-land-concessions-on-rural-livelihoods-in-cambodia-eng.pdf

[7] Cambodian Centre for Human Rights. (2016). Cambodia's Women in Land Conflict. Cambodian Centre for Human Rights. Cambodia's Women in Land Conflict (cchrcambodia.org)

[8] United Nations Industrial Development Organization. (2021) Policy Assessment for the Economic Empowerment of Women in Green Industry: Country Report-Cambodia. https://www.unido.org/sites/default/files/files/2021-06/Cambodia_Country%20Report_Final_ENG_0.pdf

[9] Lamb V., Schoenberger, L., Middleton, C., & Un, B. (2017). Gendered Eviction, Protest and Recovery: A Feminist Political Ecology Engagement with Land Grabbing in Rural Cambodia. The Journal of Peasant Studies, 44(6), 1215–1234. https://doi.org/10.1080/03066150.2017.1311868

[10] Hennings, A. (2019) The Dark Underbelly of Land Struggles: The Instrumentalization of Female Activism and Emotional Resistance in Cambodia. Critical Asian Studies, 51(1), 103-119. https://doi.org/10.1080/14672715.2018.1547881

[11] Gavalyugova, D. and Cunningham, W. (2020) Gender Analysis of the Cambodian Labor Market. World Bank. https://openknowledge.worldbank.org/entities/publication/394601c3-5797-5857-bb18-3d736ba59d4a

[12] Cambodia Indigenous Women's Association. 2022. 2020 Report on Gender-Based Violence against Indigenous Women in Three Provinces of Cambodia. https://cipocambodia.org/wp-content/uploads/2023/03/Report_on_Gender_Based_Violence_Against_Indigenous_Women_in-English_Three.pdf

[13] Huot, S, et al. (2023) Barriers of Women in Acquiring Leadership Positions in Agricultural Cooperatives: The Case of Cambodia. https://onlinelibrary.wiley.com/doi/10.1111/ruso.12490

[14] FAO. (2013) Governing Land for Women and Men: A Technical Guide to Support the Achievement of Responsible Gender-Equitable Governance of Land Tenure. Governance of Tenure Technical Guide 1. Rome. https://www.fao.org/fileadmin/user_upload/landright/docs/Technical_Guide.pdf

[15] Daley, E., Flower, C., Miggiano, L., & Pallas, S. 2013. Women's Land Rights and Gender Justice in Land Governance: Pillars in the Promotion and Protection of Women's Human Rights in Rural Areas. ILC. InternationalLandCoalition.pdf (ohchr.org)

## ឧបសម្ព័ន្ធ

មាត្រាដែលចែងសំដៅដល់អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់អនុវត្តច្បាប់នេះ ដែលនឹងត្រូវរៀបចំឡើងមានដូចជា៖

*មាត្រា ៣៥ - របបគតិយុត្តនៃដីបញ្ចុះសព* (លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីដីបញ្ចុះសព ត្រូវកំណត់ដោយអនុក្រឹត្យ)។

*មាត្រា ៤០ - សមាជិកភាពនៃសហគមន៍ជនជាតិដើមភាគតិច* (លក្ខខណ្ឌ និងនីតិវិធី ដើម្បីដាក់ពាក្យធ្វើជាសមាជិកសហគមន៍ជនជាតិដើមភាគតិច និងពាក្យសុំចាកចេញពីសហគមន៍ជនជាតិដើមភាគតិច ត្រូវកំណត់ដោយអនុក្រឹត្យ)។

*មាត្រា ៤៧ - និយមន័យនៃចំណែករួមនៃសហកម្មសិទ្ធិ* (ក្រៅពីចំណែកឯកជន សមាសភាគនៃអគារ និងក្បាលដី ដែលអគារនោះតាំងនៅជាអាទិ៍ ដែលផ្តល់អត្ថប្រយោជន៍ និងការប្រើប្រាស់សម្រាប់សហកម្មសិទ្ធិករទាំងអស់ ឬសហកម្មសិទ្ធិករមួយចំនួន ដែលបញ្ញត្តិដោយច្បាប់ ឬអនុក្រិត្យ ហៅថាចំណែករួមកំណត់ដោយច្បាប់)។

*មាត្រា ៤៨ - របបគតិយុត្តនៃកម្មសិទ្ធិអវិភាគលើចំណែករួម* (ការចាត់ថ្នាក់ និងវិសាលភាពនៃចំណែករួមត្រូវកំណត់ដោយអនុក្រឹត្យ)។

*មាត្រា ៥៤ - សិទ្ធិកម្មសិទ្ធិរបស់ជនបរទេសលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ* (សមាមាត្រ និងរបៀបគិតគូរនៃចំណែកឯកជននៃអគារសហកម្មសិទ្ធិ ដែលអាចជាកម្មសិទ្ធិរបស់បុគ្គលដែលមានសញ្ជាតិបរទេស ត្រូវកំណត់ដោយអនុក្រឹត្យ)។

*មាត្រា ៧០ - លក្ខខណ្ឌ និងនីតិវិធីសម្បទានដីសង្គមកិច្ច* (កថាខណ្ឌ ៤) លក្ខខណ្ឌ និងនីតិវិធីសម្រាប់ផ្ទេរសម្បទានដីសង្គមកិច្ចត្រូវកំណត់ដោយអនុក្រឹត្យ។

*មាត្រា ៧៣ - លក្ខខណ្ឌ និងនីតិវិធីចុះបញ្ជីសម្បទានដីសេដ្ឋកិច្ច* (កថាខណ្ឌ ៣) លក្ខខណ្ឌ និងនីតិវិធីសម្រាប់ចុះបញ្ជីសម្បទានដីសេដ្ឋកិច្ច ត្រូវកំណត់ដោយអនុក្រឹត្យ។

*មាត្រា ៩០ - រចនាសម្ព័ន្ធនៃរដ្ឋបាលសុរិយោដី* (កថាខណ្ឌ ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាលសូរិយោដី ត្រូវកំណត់ដោយអនុក្រឹត្យ។

*មាត្រា ៩៥ - សមត្ថកិច្ចរបស់រដ្ឋបាលសុរិយោដី* (សមត្ថកិច្ចផ្សេងទៀតរបស់រដ្ឋបាលសុរិយោដី ត្រូវកំណត់ដោយអនុក្រឹត្យ)

*មាត្រា ៩៩ - លក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់សេវាសាធារណៈ ដោយរដ្ឋបាលសុរិយោដី* (លក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់សេវាសាធារណៈដោយរដ្ឋបាលសុរិយោដី ត្រូវកំណត់ដោយអនុក្រឹត្យ)។

*មាត្រា ១៣០ - ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ* (រយៈពេលបិទផ្សាយជាសាធារណៈនៅឯកសារនៃការវិនិច្ឆ័យ ត្រូវកំណត់ដោយអនុក្រឹត្យ)

*មាត្រា ១៣២ - លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ* (លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ត្រូវកំណត់ដោយអនុក្រឹត្យ)

*មាត្រា ១៣៧ - ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ត្រូវធ្វើការបិទផ្សាយជាសាធារណៈ* (លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ត្រូវកំណត់ដោយអនុក្រឹត្យ)

*មាត្រា ១៤៣ - ការបែកក្បាលដីសហកម្មសិទ្ធិក្នុងករណីមានការដកហូត ដើម្បីផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ។* ក្នុងករណីមានការដកហូតកម្មសិទ្ធិមួយផ្នែកលើដីសហកម្មសិទ្ធិ ដើម្បីផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ សហកម្មសិទ្ធិករត្រូវស្នើសុំបំបែកក្បាលដីសហកម្មសិទ្ធិមួយផ្នែក ហើយធ្វើអនុប្រធានក្បាលដីនោះឱ្យរដ្ឋ ឬនីតិបុគ្គលសាធារណៈដទៃទៀតដាច់ដោយឡែកពីចំណែកឯកជន។ (លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីចំណែកឯកជននៃសហកម្មសិទ្ធិ ត្រូវកំណត់ដោយអនុក្រឹត្យ)

*មាត្រា ១៤៦ - ដីដែលត្រូវចុះបញ្ជីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច* (ទំហំសរុបអតិបរមានៃព្រៃអារក្ស និងដីកប់សពដែលអាចចុះបញ្ជីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ត្រូវកំណត់ដោយអនុក្រឹត្យ)។

*មាត្រា ១៤៧ - បទបញ្ញាផ្ទៃក្នុងរបស់សហគមន៍ជនជាតិដើមភាគតិច* (គំរូបទបញ្ញាផ្ទៃក្នុងរបស់សហគមន៍ជនជាតិដើមភាគតិចដែលដាក់ពាក្យសុំចុះបញ្ជីដីសហគមន៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់)។

*មាត្រា ១៤៨ - លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច* (លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ត្រូវកំណត់ដោយអនុក្រឹត្យ)។

*មាត្រា ១៥១ - ការកែតម្រូវ ការចុះបញ្ជី* (លក្ខខណ្ឌ និងនីតិវិធីនៃការកែតម្រូវការចុះបញ្ជីដីធ្លីដំបូង ត្រូវកំណត់ដោយអនុក្រឹត្យ)។